ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

## សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល

## ស្តីពី

## ការរកឃើញ ០១ ករណីថ្មីទៀត ជាស្ត្រីជនជាតិបារាំងដែលជាម្តាយរបស់ទារកអាយុ ០៤ខែ និង ០២ ករណីថ្មី ជាបុរសជនជាតិខ្មែរ វិជ្ជមានវីរុសកូវីដ១៩

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ ឲ្យបានជ្រាបថា លទ្ធផលពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា នាថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ វេលាយប់ម៉ោង១៩:៣០នាទី បានបង្ហាញថាសំណាកវត្ថុវិភាគរបស់ស្ត្រីជនជាតិបារាំងចំនួន ០១នាក់ និងបុរសជនជាតិខ្មែរចំនួន ០២នាក់ វិជ្ជមានវីរុសកូវីដ១៩ ជាករណីថ្មីបន្ថែមទៀត ដែលមានដូចខាងក្រោមនេះ៖

### ១. នៅខេត្តកំពង់ចាម៖ ០១ ករណី ជាជនជាតិខ្មែរ

បុរសជនជាតិខ្មែរ អាយុ ៥៥ឆ្នាំ វិជ្ជមានវីរុសកូវីដ១៩ រស់នៅឃុំពាមជីកង ស្រុកកងមាស ជាអ្នកដែលបានចូលរួមពិធីសាសនាជាមួយជនជាតិម៉ាឡេស៊ីមកពីប្រទេសម៉ាឡេស៊ីដែលបានប្រព្រឹត្តទៅនៅស្រុកកងមាសពីថ្ងៃទី១២ ដល់ទី១៦ ខែមីនា ឆ្នាំ២០២០។ គាត់រស់នៅជាមួយកូនស្រីអាយុ ១១ឆ្នាំ ដែលបច្ចុប្បន្ននេះ ក្រុមការងារបានយកសំណាកវត្ថុវិភាគកូនស្រីនេះរួចហើយ និងកំពុងរង់ចាំលទ្ធផល។ បុរសរូបនេះ ត្រូវបាន និងកំពុងដាក់នៅដាច់ដោយឡែកព្យាបាលនៅមន្ទីរពេទ្យខេត្តកំពង់ចាម។

### ២. នៅខេត្តកោះកុង៖ ០១ ករណី ជាជនជាតិខ្មែរ

បុរសជនជាតិខ្មែរ អាយុ ៣៦ឆ្នាំ រស់នៅខេត្តកំពត មានតេស្តវិជ្ជមានវីរុសកូវីដ១៩។ បច្ចុប្បន្នបុរសរូបនេះ កំពុងសម្រាកព្យាបាលក្នុងមន្ទីរពេទ្យខេត្តកោះកុង។ រូបគាត់ មិនបានទៅប្រទេសម៉ាឡេស៊ីទេ គឺជាករណីចម្លងពីការនៅជិតស្និទ្ធហែរហមជាមួយបុរសអាយុ ៥៧ឆ្នាំ ដែលវិជ្ជមានវីរុសកូវីដ១៩ នៅខេត្តកោះកុង ដែលបានវិលត្រឡប់មកពីចូលរួមពិធីសាសនានៅប្រទេសម៉ាឡេស៊ី។

សរុបចំនួនអ្នកប៉ះពាល់ផ្ទាល់ទាំងអស់ ១០នាក់ (មាន ០៩នាក់ អវិជ្ជមានវីរុសកូវីដ១៩) និងអ្នកប៉ះពាល់ប្រយោលសរុបចំនួន១៣នាក់ (ក្នុងចំនួននេះ មានគ្រូពេទ្យម្នាក់) ដែលមានតេស្តអវិជ្ជមានកូវីដ១៩។

### ៣. នៅរាជធានីភ្នំពេញ៖ ០១ ករណី ជាម្តាយរបស់ទារកអាយុ ០៤ខែ

ស្ត្រីជនជាតិបារាំង អាយុ ២៨ឆ្នាំ ជាម្តាយរបស់ទារកអាយុ ០៤ខែ មានតេស្តវិជ្ជមានវីរុសកូវីដ១៩ ដែលកំពុងនៅថែទាំកូនដែលវិជ្ជមានវីរុសកូវីដ១៩ សម្រាកព្យាបាលនៅមន្ទីរពេទ្យគន្ធបុប្ផាភ្នំពេញ។ ស្វាមីរបស់គាត់ជាជនជាតិបារាំង អាយុ ៣៥ឆ្នាំ ដែលមានវីរុសកូវីដ១៩ កំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀតនៅឡើយ។



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) [illegible] / ៨៨៤ ៩០៩

## ៤. សរុបករណីវិជ្ជមានវីរុសកូវីដ១៩ នៅទូទាំងប្រទេស៖

ត្រឹមម៉ោង២០:៣០ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ ករណីវិជ្ជមានវីរុសកូវីដ១៩ សរុបទាំងអស់មានចំនួន ៨៧នាក់ (ស្រី ២២នាក់ ប្រុស ៦៥នាក់) ដែលក្នុងនោះ មានជនជាតិ ចិន ០១នាក់ (នៅខេត្តព្រះសីហនុ បានជាសះស្បើយ) អង់គ្លេស ០៣នាក់ (ក្នុងនេះ មាន ០១នាក់ បានជាសះស្បើយហើយ) កាណាដា ០១នាក់ បែលហ្ស៊ិក ០១នាក់ បារាំង ៣៤នាក់ (ក្នុងនេះមានកូនប្រុសបង្កើតអាយុ០៤ខែ) ម៉ាឡេស៊ី ១២នាក់ និង ខ្មែរ ៣៥នាក់។

ក្រុមការងាររបស់ក្រសួងសុខាភិបាល កំពុងតែធ្វើកិច្ចការស្រាវជ្រាវករណីថ្មីជាបន្តទៀត ហើយនឹងបន្តជម្រាបជូនដល់បងប្អូនសាធារណជន ប្រសិនបើមានរកឃើញករណីវិជ្ជមានវីរុសកូវីដ១៩ ថ្មីណាផ្សេងទៀត។

ក្រសួងសុខាភិបាលសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវឌ្ឍនៃបញ្ហាសុខភាព តាមទំព័រហ្វេស ប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃចន្ទ ១៥រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២០

ចំនួនសរុបករណីវិជ្ជមានកូវីដ ១៩ តាមថ្ងៃដែលបានរកឃើញ




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា
## គិតដល់ថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២០

ចំនួនករណីវិជ្ជមានកូវីដ ១៩ ថ្មី តាមថ្ងៃដែលបានរកឃើញ




ប្រភពៈ ក្រសួងសុខាភិបាល

# ស្ថានភាពស្តីពីជំងឺកូវីដ ១៩ នៅកម្ពុជា

## ចំនួនករណីវិជ្ជមានកូវីដ១៩ សរុប ៨៧ ករណី គិតដល់ថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២០




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២០

### ករណីវិជ្ជមានកូវីដ ១៩ តាមភេទ
### ក្នុងចំណោម ៨៧ ករណី

ភេទស្រី ២២ ករណី (ស្មើនឹង ២៥%)




ភេទប្រុស ៦៥ ករណី (ស្មើនឹង៧៥%)

ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ២២ ខែមីនា ឆ្នាំ២០២០

### ភាគរយនៃករណីវិជ្ជមានកូវីដ ១៩ តាមជនជាតិ
### ក្នុងចំណោម ៨៧ ករណី




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ២២ ខែមីនា ឆ្នាំ២០២០

ចំនួនករណីដែលបានជាសះស្បើយ និង
ករណីដែលកំពុងព្យាបាល

**សរុប៖ ៨៧ ករណី**




| | |
|---|---|
| ករណីកំពុងព្យាបាល | ៨៥ |
| ករណីជាសះស្បើយ | ២ |

ប្រភព៖ ក្រសួងសុខាភិបាល